**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

រឿងព្រហ្មទណ្ឌ
លេខសំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦១០
ចុះថ្ងៃទី ២៩_០៩_២០០៩
សាលដីកា
លេខ: ៧៥ "ក្រ.III.ស"
ចុះថ្ងៃទី ៣០_១១_២០១១

# នាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៤_១១_២០១១ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រុមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រុមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted]

ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦១០ ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០៩ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] **ឃី** ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកោះស្វាយ ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ ទីលំនៅសព្វថ្ងៃភូមិ[redacted]ស្រុកមោងឫស្សី ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted]មានកូន ៥នាក់ ចាប់ខ្លួនថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៩ ឃុំខ្លួនថ្ងៃទី ១៩ ខែមករា ឆ្នាំ២០០៩។

មានលោក[redacted] ចន្ថា ជាមេធាវីការពារ។

<u>**ជាប់ចោទពីបទ:**</u> **ប៉ុនប៉ងធ្វើមនុស្សឃាតដោយគិតទុកជាមុន** ប្រព្រឹត្តនៅភូមិមុខរាហ៏ ២ ឃុំព្រៃត្រឡាច ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ខុម** ភេទស្រី អាយុ ៤៤ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃ ភូមិស្រះគុយ ឃុំព្រៃត្រឡាច ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ល

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ១១៩ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ឃី ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៩ "ង" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

**ដំណើររឿងមានដូចតទៅ:**

កាលពីថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០៩ ឈ្មោះ [redacted] ឃី មានទំនាស់គ្នាជាមួយឈ្មោះ [redacted] រ៉េត ដោយបានជាល់គ្នាទៅវិញទៅមក ពេលនោះឈ្មោះ [redacted] រ៉េត ក៏បានជាល់ត្រូវរង្វង់ភ្នែកឈ្មោះ [redacted] ឃី មួយដៃបណ្តាលឱ្យឈ្មោះ [redacted] ឃី មានគំនុំ ។ លុះដល់ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៩ វេលាម៉ោងប្រហែល ១០យប់ ឈ្មោះ [redacted] ឃី ក៏បានស្ពាយកាំភ្លើងអាកាមួយដើម និងពាក់កែវឆ្លុះនៅក្បាល ដើរសំដៅទៅរោងចិញ្ចឹមទារបស់ឈ្មោះ [redacted] រ៉េត ហើយបានបាញ់ទៅលើឈ្មោះ [redacted] រ៉េត មួយគ្រាប់ចំត្រគៀកខាងឆ្វេងធ្លុះឆ្អឹងថាល បន្ទាប់មកក៏ឈ្មោះ [redacted] ឃី រត់គេចខ្លួនចេញពីកន្លែងកើតហេតុ ឯជនរងគ្រោះត្រូវបានក្រុមគ្រួសារយកទៅព្យាបាលនៅមន្ទីរពេទ្យ ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៦៩ "ង" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសលើឈ្មោះ [redacted] ឃី ភេទប្រុស អាយុ ៣៩ឆ្នាំ ដាក់ពន្ធនាគារតម្រូវឱ្យធ្វើការកំណត់ ១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនពីថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៩ ។

ពីបទ **ប៉ុនប៉ងធ្វើមនុស្សឃាតដោយគិតទុកជាមុន** ប្រព្រឹត្តនៅភូមិមុខរាហ៍ ២ ឃុំព្រៃត្រឡាច ស្រុកមោងឫស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

២- បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ឃី នេះ រហូតដល់អនុវត្តទោសខាងលើចប់ជាស្ថាពរ ។

៣- បង្គាប់ឱ្យឈ្មោះ [redacted] ឃី សងសំណងរដ្ឋប្បវេណីជាប្រាក់ចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល) ទៅឈ្មោះ **ហៃ ខុម** ជាដើមបណ្តឹងរដ្ឋប្បវេណី ។

ការទាមទារលើសពីនេះត្រូវច្រានចោល ។

៤- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឃី កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុម ។ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ១១៩ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ឃី ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៦៩ "ង" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍ ។
- បានស្តាប់របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ឃី បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង ។

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខុម បានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់អង្គសវនាការ និងក្រោយពីបានស្តាប់របាយការណ៍ ឃើញថា សាលក្រមរបស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដូច្នេះ សុំតម្កល់សាលក្រមនេះទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ឆ្លងតាមការស្តាប់របាយការណ៍ និងការចោទប្រកាន់របស់តំណាងអយ្យការ តាមចម្លើយរបស់កូនក្តីខ្លួនបានឆ្លើយបដិសេធថា នៅថ្ងៃកើតហេតុកូនក្តីខ្លួនមិនបានធ្វើសកម្មភាពទេ គឺនៅផ្ទះរបស់ខ្លួន និងមានសាក្សីបញ្ជាក់ច្បាស់លាស់ហើយពីផ្ទះរបស់កូនក្តីខ្លួន និងផ្ទះរបស់ជនរងគ្រោះមានចម្ងាយ ១១គីឡូម៉ែត្រ ធ្វើដំណើរទៅរយៈពេល ៤៥នាទី ទើបទៅដល់. ពេលឮសម្លេងផ្ទុះកាំភ្លើង កូនក្តីខ្លួនក៏បានចេញទៅមើលដែរ ។ ហើយតាមចម្លើយរបស់ជនរងគ្រោះឆ្លើយថា កូនក្តីខ្លួនជាអ្នកប្រព្រឹត្ត គឺបើកូនក្តីខ្លួនដាក់ភ្លើង គឺមិនអាចធ្វើឱ្យមើលឃើញមុខច្បាស់នោះទេ គឺស្រវាំងភ្នែកទៅហើយ ដោយតុលាការសម្រេច ដោយសំអាងថា កូនក្តីខ្លួនធ្លាប់មានទំនាស់ជាមួយជនរងគ្រោះ តែកូនក្តីខ្លួនបានធ្វើការសម្របសម្រួលគ្នារួចរាល់ហើយនៅភូមិឃុំ ។ ចំពោះសាក្សីសុទ្ធតែជាសាក្សីរបស់ជនរងគ្រោះ សូមក្រុមប្រឹក្សាពិចារណា ។ មាត្រា ៨២. ១១៨. ៨២. ០៣ នៃក្រមព្រហ្មទណ្ឌ សុំក្រុមប្រឹក្សាឱ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់ផង ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

## សាលាឧទ្ធរណ៍ភ្នំពេញ

### យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍លេខ ១១៩ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ឃី ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- កាលពីថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៩ មានអំពើឃាតកម្មគិតទុកជាមុន បានកើតឡើងទៅលើជនរងគ្រោះ ឈ្មោះ [redacted] រ៉េត ប្រព្រឹត្តដោយជនជាប់ចោទ ដោយប្រើកាំភ្លើង AK ជាអាវុធប្រហារ ។

ករណីនេះជនជាប់ចោទថា នៅថ្ងៃកើតហេតុខ្លួននៅជួបជុំផឹកស៊ីជាមួយមិត្តភក្តិ តែខ្លួនមិនបានចូលរួមផឹកស៊ីទេ ដោយទៅមើលមេគោកើតកូនរហូតដល់ម៉ោង ១១យប់ មិនបានចេញទៅណាទេ. នៅយប់នោះខ្លួនស្លៀកខោជើងខ្លី ពាក់អាវវងាពីក្រៅ ។ នេះគ្រាន់តែជាចម្លើយដោះសាររបស់ជនជាប់ចោទប៉ុណ្ណោះ ដោយហេតុថា តាមចម្លើយសាក្សី ដើមបណ្ដឹង និងជនរងគ្រោះផង បានបញ្ជាក់ច្បាស់ដូចគ្នាថា នៅពេលនោះពួកខ្លួនមើលឃើញ និងស្គាល់ច្បាស់ គឺជនជាប់ចោទស្លៀកខោវែង ពាក់អាវវងាពណ៌ខ្មៅដៃវែង កាន់កាំភ្លើង AK ប្រហារជនរងគ្រោះ និងមានពាក់ភ្លើងឆ្លុះនៅនឹងក្បាលផង ។ ឯសាក្សីដោះបន្ទុកឆ្លើយមិនបានបង្ហាញការណ៍ពិតឡើយ គឺជាសាក្សីរៀបចំ ដោយសាក្សីខ្លះថា ផឹកស្រាក្លែមសាច់មាន់ឆា ឯសាក្សីខ្លះថា ផឹកស្រាក្លែមត្រីប្រឡាក់ គ្មានសាច់មាន់ទេ ។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ **ប៉ុនប៉ងឃាតកម្មគិតទុកជាមុន** ប្រព្រឹត្តនៅភូមិមុខរាហ៍ ២ ឃុំព្រៃត្រឡាច ស្រុកមោងឬស្សី ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៩ បទល្មើសមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤- សំអាងហេតុ និងសេចក្ដីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ៦៩ "ង" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង មានភាពច្បាស់លាស់ និងត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងឧទ្ធរណ៍លេខ ១១៩ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ឃី ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៦៩ "ង" ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣- បង្គាប់ឱ្យបន្តនូវការឃុំខ្លួនជនជាប់ចោទ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ 02 ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]